# ព្រះរាជាណាចក្រកម្ពុជា៖ អ្នករាយការណ៍ពិសេសរបស់ អ.ស.ប បំពេញបេសកកម្មស្វែងរកការពិត

ទីក្រុងហ្សឺណែវ (០១ ធ្នូ ២០១១) – អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ សុរិយា ស៊ូបេឌី នឹងបំពេញទស្សនកិច្ចផ្លូវការមកកាន់ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១។

"ទន្ទឹមនឹងដំណើរបេសកកម្មរបស់ខ្ញុំ ផ្តោតលើការវិភាគលើប្រព័ន្ធបោះឆ្នោត និងស្ថាប័នពាក់ព័ន្ធតាមទស្សនវិស័យសិទ្ធិមនុស្ស ខ្ញុំនឹងបន្តតាមមើលផងដែរ អំពីទិដ្ឋភាពផ្សេងទៀតនៃស្ថានភាពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា" លោកសាស្ត្រាចារ្យ ស៊ូបេឌី បានមានប្រសាសន៍ នៅពេលដែលលោកធ្វើការប្រកាសពីដំណើរទស្សនកិច្ចលើកទី៦ របស់លោកមកកាន់ប្រទេសនេះ។

ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជាលើកនេះ អ្នករាយការណ៍ពិសេសជួបប្រាស្រ័យការងារជាមួយអាជ្ញាធររដ្ឋាភិបាល អង្គការសង្គមស៊ីវិល គណៈកម្មាធិការរៀបចំការបោះឆ្នោតជាតិ និងខេត្ត និងក្រុមប្រឹក្សាធម្មនុញ្ញ។ លោកក៏រំពឹងផងដែរថា នឹងជួបពិភាក្សាការងារជាមួយអគ្គស្នងការនគរបាលជាតិ។

នៅចុងបញ្ចប់នៃដំណើរទស្សនកិច្ចរបស់លោក លោកស៊ូបេឌី នឹងចេញសេចក្តីប្រកាសព័ត៌មានមួយដែលនឹងគូសបញ្ជាក់អំពីបញ្ហាមួយចំនួនដែលបានលើកឡើង នៅក្នុងពេលបំពេញបេសកកម្មរបស់លោក។ ព័ត៌មានដែលលោកប្រមូលបាន ក្នុងពេលបំពេញបេសកកម្មមកកាន់ព្រះរាជាណាចក្រកម្ពុជា នឹងបញ្ចូលក្នុងរបាយការណ៍របស់លោក ដែលនឹងដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងខែកញ្ញា ឆ្នាំ២០១២។(ចប់)

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូបេឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមីនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកមិនចំណុះឲ្យរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកគឺជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិ នៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស។*

*សិទ្ធិមនុស្ស អ.ស.ប៖ គេហទំព័រតាមប្រទេស-កម្ពុជា៖* *http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

*សំរាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមមេត្តាទាក់ទង៖*

*នៅភ្នំពេញ៖ Ms Zoe Latumbo, (+855 12 790 178 / zlatumbo@ohchr.org)*

*នៅហ្សឺណែវ៖* Robert Vaughan *(+41 22 928 9188 / rvaughan@ohchr.org)*)

សំរាប់ការសាកសួរព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង Xabier Celaya សិទ្ធិមនុស្ស អ.ស.ប – អង្គភាពព័ត៌មានតាមរយៈ(+ 41 22 917 9383 / xcelaya@ohchr.org)

សិទ្ធិមនុស្ស អ.ស.ប-ការតាមដានព័ន៌មានសង្គម
ហ្វេសប៊ុក ៖ https://www.facebook.com/unitednationshumanrights
ទ្វីតធ័រ ៖ http://twitter.com/UNrightswire
យូធូប ៖ http://www.youtube.com/UNOHCHR